## ការបញ្ចប់ដំណោះស្រាយក្នុងស្រុក (exhaustion of local remedy)

គោលការណ៍បញ្ចប់ដំណោះស្រាយក្នុងស្រុក ជាគោលការណ៍មួយ ទាមទារថា មុននឹងប្ដឹង ឬសុំឲ្យរដ្ឋជួយតាមផ្លូវទូត (diplomatic protection) បុគ្គលរងគ្រោះ ត្រូវប្ដឹង និងបញ្ចប់ដំណោះស្រាយក្នុងស្រុកនៃប្រទេសដែលបំពានសិទ្ធិសិន។ គោលការណ៍នេះ មានចែងក្នុងសន្ធិសញ្ញាជាច្រើន និងស្ទើរគ្រប់វិស័យ។ មាត្រា៤១ នៃកតិកាសញ្ញាពីសិទ្ធិមនុស្សនិងប្រជាពលរដ្ឋបានចែងផងដែរ (international covenant on civil and political rights: ICCPR)។

គោលការណ៍នេះ មានវ័យចំណាស់ និងទទួលស្គាល់ជាទូទៅដោយរដ្ឋ និងជាវិធានទំនៀមទម្លាប់អន្តរជាតិ។ វាជាគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ (general principle of international law)។ មូលហេតុដែលទាមទារដូចនេះ មានមូលដ្ឋានចេញពីទ្រឹស្ដីអធិបតេយ្យភាព ដែលតម្រូវឲ្យមានការស្នើដោះស្រាយដោយយន្តការក្នុងស្រុក ឬទុកឱកាសជូនរដ្ឋនោះ កែតម្រូវមុនពេល រដ្ឋដទៃលូកដៃចូលអន្តរាគមដោះស្រាយ។ នេះវាស្រដៀងគ្នា នឹងយន្តការក្នុងស្រុក ដែលតុលាការមុននឹងដោះស្រាយវិវាទរដ្ឋបាលប្ដឹងប្រឆាំងអាជ្ញាធររដ្ឋ បុគ្គលត្រូវប្ដឹងបញ្ចប់តាមយន្តការរដ្ឋបាលជាមុនសិន។

គោលការណ៍នេះអនុវត្តក្នុងករណី ដែលរដ្ឋមួយបំពានវិធានអន្តរជាតិ និងប៉ះពាល់ដល់ជនបរទេស ឬការបំពានច្បាប់អន្តរជាតិកើតនៅក្រៅដែនដីនៃរដ្ឋទទួលខុសត្រូវ និងទំនាស់រវាងរដ្ឋ និងជនបរទេសមិនមែនទំនាស់រវាងរដ្ឋ និងរដ្ឋទេ។ និយាយជាសាមញ្ញ ក្នុងករណីចុងក្រោយនេះ រដ្ឋនឹងមិនត្រូវបានបង្ខំឲ្យប្ដឹងក្នុងស្រុក មុននឹងប្ដឹងទៅអន្តរជាតិ ប្រឆាំងនឹងរដ្ឋជាគូរជម្លោះទេ។

ដំណោះស្រាយនេះ មានន័យទូលាយ មានដំណោះស្រាយតាមផ្លូវរដ្ឋបាល ឬតាមផ្លូវតុលាការ។ អ្វីដែលជាសំខាន់គឺថា បើមានយន្តការដំណោះស្រាយហើយ បុគ្គលត្រូវតែប្រើប្រាស់ ដើម្បីកុំឲ្យមានការអះអាងថា បុគ្គលមិនទាន់ប្ដឹងដោះស្រាយបញ្ចប់ដំណោះស្រាយក្នុងស្រុក ដូចនេះបណ្ដឹងត្រូវបានបដិសេធ។ វានឹងមិនខុសច្បាប់ទេ ក្នុងការចរចារ (negotiation) ដែលមានលក្ខណៈបង្ហា មិនត្រូវបានរាប់ជាដំណោះស្រាយទេ។ ដូចគ្នានេះដែរ ករណីខ្លះ ការបញ្ចប់ដំណោះស្រាយក្នុងស្រុក អាចត្រូវបានរំលងក្នុងករណីដែលហានិភ័យនឹងកើតភ្លាមៗ ឬមិនអាចជុសជុលវិញបាន (irreparable harm)។

ឧបសគ្គ អាចកើតមានឡើង ដោយសារ ពេលវេលាប្ដឹងបានកន្លងទៅ ឬ មានប្រធានសក្តិ (force majeur) ដែលរារាំងមិនអាចប្ដឹងបាន នាំមិនឲ្យអាចបញ្ចប់ដំណោះស្រាយដូចការទាមទារ។

បន្ថែមពីលើនេះ ការតម្រូវឲ្យបញ្ចប់ នឹងមិនចាំបាច់ក្នុងករណីថា សេចក្ដីសម្រេចនាពេលខាងមុខពិតជាមិនជាប្រយោជន៍ឬអយុត្តិធម៌ (denial of justice) ឬគ្មានដំណោះស្រាយ ដោយសារ ការចោទ

ប្រកាន់ត្រូវបានលុបចោល ដោយច្បាប់លើកលែងទោស ដំណោះស្រាយនោះ មានភាពយឺតយូរជាដើម (encyclopedia of PIL, pp. 238-241)។